# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍
# សុន្ទរកថាអំពីការអនុវត្តបទបញ្ជាលេខ ១ ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១២ របស់
# នាយករដ្ឋមន្ត្រី ទាក់ទងនឹងវិធានការ ដើម្បីពង្រឹង
# និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច

*ថ្លែងដោយ ឯកឧត្តម បណ្ឌិត វ៉ុលហ្វហ្កាង ម៉ូហ្សេ ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំនៅកម្ពុជា*

*នៅក្នុង*

*កិច្ចប្រជុំលើកទី ១៩ នៃ*

*គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍*

*ភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២*

*សូមគោរព*

*ឯកឧត្តម គាត ឈន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ឯកឧត្តម អ៊ឹង ឃុនលឹម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*ឯកឧត្តម លោក លោកស្រី!*

១. ក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកជាចំបងលើកសិកម្ម កាលានុវត្តភាពសម្រាប់ជនសាមញ្ញកម្ពុជា ក្នុងការទទួលផលពីកំណើនសេដ្ឋកិច្ចដោយចីរភាព និងសម្រាប់ទាំងអស់គ្នា នឹងពឹងអាស្រ័យជាចំបងទៅលើវិសាលភាពនៃសិទ្ធិក្នុងការទទួលបានកម្មសិទ្ធិដី។ រាជរដ្ឋាភិបាលកម្ពុជាសមនឹងទទួលបាននូវការកោតសរសើរដោយសារតែវឌ្ឍនភាព ដែលសម្រេចបានក្នុងការផ្តល់សន្តិសុខលើកម្មសិទ្ធិដី និងក្នុងការដោះស្រាយទំនាស់រវាងអ្នកជិតខាង តាមរយៈកម្មវិធីចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ។ ដោយបានបែងចែកប័ណ្ណកម្មសិទ្ធិដីចំនួនច្រើនជាង២លានច្បាប់ គេពុំឃើញមានករណីនៃការទន្ទ្រានយកដីដោយល្មើសច្បាប់ ដែលជាប្រភពនៃទំនាស់ និងការជម្លៀសចេញថ្មីៗឡើយ។ ដូច្នេះ យើងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ត និងបង្កើនល្បឿននៃការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និងសូមរម្លឹកឡើងវិញថា យើងត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងគោលដៅបង្ហើយការចុះបញ្ជីដីធ្លីជាលើកដំបូងនៅក្នុងរយៈពេល ១០ឆ្នាំខាងមុខនេះ។

២. របាយការណ៍វឌ្ឍភាពនៃសូចនាករពិនិត្យតាមដានរួមគ្នា (JMI) ក៏ឆ្លុះបញ្ចាំងផងដែរថា ចាប់តាំងពីកិច្ចប្រជុំ GDCC ចុងក្រោយមក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនជាច្រើន ក្នុងការពង្រឹងជាបន្ថែមទៀតនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ៖ គោលនយោបាយកសាងផែនការរូបវន្តត្រូវបានអនុម័ត ហើយការងារកសាងក្របខ័ណ្ឌច្បាប់នានាក៏បានផ្តួចផ្តើមឡើងផងដែរ។ ប្រការទាំងអស់នេះរួមគ្នានឹងផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំដែលចាំបាច់សម្រាប់រដ្ឋាភិបាលប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេច អំពីការកសាងផែនការប្រើប្រាស់ដីធ្លី ទន្ទឹមនឹងគិតគូរផងដែរអំពីលក្ខខណ្ឌសង្គម បរិស្ថាន និងសេដ្ឋកិច្ចបានគ្រប់ជ្រុងជ្រោយ និងមានតម្លាភាព។ ចំពោះតំបន់ទីក្រុង ក្របខ័ណ្ឌនេះនឹងមានការបំពេញបន្ថែមតាមរយៈគោលនយោបាយជាតិ ស្តីពីទីជម្រក ដែលទទួលស្គាល់សិទ្ធិក្នុងការទទួលបានទីជម្រកគ្រប់គ្រាន់ និងដែលកំពុងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ដៃគូនានាក៏សូមកោតសរសើរផងដែរចំពោះការងារកសាងគោលនយោបាយវាយតម្លៃដីធ្លី ដែលមានសក្តានុពលយ៉ាងច្រើនមកលើសារពើពន្ធ និងអំពីកំណែលម្អការចុះបញ្ជីដីធ្លីជាបន្តបន្ទាប់ ដែលមានសារៈសំខាន់បំផុតសម្រាប់ការរក្សាបាននូវទំនុកចិត្តមកលើប្រព័ន្ធសុរិយោដី។

៣. យើងក៏សូមអបអរសាទចំពោះរាជរដ្ឋាភិបាលកម្ពុជាផងដែរ ចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្រាប់ដីកម្មសិទ្ធិសមូហភាព ដល់ពលរដ្ឋជាជនជាតិដើមភាគតិច កាលពីចុងឆ្នាំ ២០១១ និងដើមឆ្នាំ ២០១២ - នេះពិតជាសមិទ្ធផលគួរឲ្យកត់សំគាល់! ដោយសារឥឡូវនេះមាននីតិវិធីច្បាស់លាស់ យើងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលក្នុងការបន្តកិច្ចការដ៏មានសារៈសំខាន់នេះនិងពង្រីកការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ដោយហេតុថា មានសហគមន៍ជនជាតិដើមភាគតិចជាចំនួនច្រើនដែលបានចុះបញ្ជីនៅក្រសួង

មហាផ្ទៃ ដើម្បីមានលក្ខណៈស្របច្បាប់ ការផ្តល់វិធានការការពារជាបណ្តោះអាសន្នចំពោះមុខដល់សហគមន៍ទាំងនេះគឺជាប្រការសំខាន់។

៤. យើងទទួលស្គាល់ថា វិស័យដីធ្លីមានលក្ខណៈស្មុគស្មាញ និងទាមទារឲ្យមានអភិក្រមដែលមានតម្លាភាព និងទូលំទូលាយ ក៏ដូចជា យន្តការនយោបាយ ដើម្បីសម្របសម្រួលការងារអន្តរក្រសួង និងផ្សារភ្ជាប់រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ថ្មីៗនេះ ការយកចិត្តទុកដាក់របស់សាធារណជនបានផ្តោតលើឥទ្ធិពលអវិជ្ជមានខាងសង្គម និងបរិស្ថាន ដែលទាក់ទងនឹងការផ្តល់សម្បទាននានា ជាពិសេសដីសម្បទានសេដ្ឋកិច្ច។ ក្នុងករណីខ្លះ ប្រការនេះបង្កការប៉ះពាល់ដល់កម្មវិធីនានា ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍។ ក្នុងពេលដែលរាជរដ្ឋាភិបាលមានបំណងយ៉ាងត្រឹមត្រូវក្នុងការលើកកំពស់ការវិនិយោគដោយផ្ទាល់ បង្កើនផលិតភាព បង្កើតការងារ និងកាលានុវត្តភាពប្រាក់ចំណូលនៅក្នុងវិស័យកសិកម្ម អ្នករិះគន់បានចង្អុលបង្ហាញពីកំណើនទំនាស់ដីធ្លីនៅក្នុងតំបន់នានាដែលអង្គភាពរដ្ឋ និងក្រុមហ៊ុនឯកជនធំៗ ទាមទារយកដីដែលជាញឹកញាប់កាន់កាប់ដោយពលរដ្ឋក្រីក្រ និងដែលងាយរងគ្រោះ។ នៅក្នុងករណីជាច្រើន ប្រការនេះពិតជាបាននាំឲ្យមានការប្តូរទីលំនៅដោយបង្ខំ។ នេះជាកង្វល់សម្រាប់ដៃគូអភិវឌ្ឍន៍ដែលមានគោលបំណងជួយគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ។ ការទទួលស្គាល់កាន់តែច្រើនឡើងអំពី**សិទ្ធិមនុស្សក្នុងការទទួលបានស្បៀងអាហារ និងទីជម្រកគ្រប់គ្រាន់** ទាមទារឲ្យមានកិច្ចប្រឹងប្រែងថែមទៀតដើម្បីអនុវត្តក្របខ័ណ្ឌច្បាប់ដែលមានស្រាប់។

៥. ដោយផ្អែកលើមូលដ្ឋានខាងលើនេះ "សុន្ទរកថាអំពីដីធ្លី" និងបទបញ្ជាលេខ ០១ របស់នាយករដ្ឋមន្ត្រី បានបង្កើតឲ្យមានការយកចិត្តទុកដាក់ជាច្រើន។ ក្នុងពេលនេះ យើងសូមថ្លែងអំណរគុណចំពោះឯកឧត្តមទេសរដ្ឋមន្ត្រីដែលបានផ្តល់សុន្ទរកថាពិស្តារ និងកាលានុវត្តភាពសម្រាប់ដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងយល់បានប្រសើរថែមទៀតអំពីគោលដៅនានានៃបទបញ្ជានេះ និងអំពីរបៀបអនុវត្តបទបញ្ជានេះ។ កម្លាំងជម្រុញដែលបទបញ្ជានេះបានបង្កើតឡើង មានទំហំធំធេងណាស់ ហើយអត្ថប្រយោជន៍ដែលបទបញ្ជានេះផ្តល់ឲ្យ ក៏មានទំហំធំធេងផងដែរ៖ យើងសូមស្វាគមន៍ចំពោះការផ្អាកជាបណ្តោះអាសន្នលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗជាបន្ថែមទៀត ដោយសារចំណាត់ការនេះអាចបញ្ឈប់ទំនាស់ថ្មីៗមិនឲ្យកើតឡើងបាន។ ដោយពិចារណាអំពីជនកម្ពុជាក្រីក្រជាច្រើនដែលមានដីធ្លីតិចតួច ឬដែលគ្មានដីធ្លី យើងក៏ជឿផងដែរថា ការបែងចែកដីរដ្ឋដល់គ្រួសារចំនួន ៣៥០.០០០ អាចជម្រុញឲ្យមានកំណើនសន្តិសុខលើកម្មសិទ្ធិដីធ្លី អាចមានឥទ្ធិពលដល់ការបែងចែកដីឡើងវិញ និងរួមចំណែកក្នុងការកាត់បន្ថយវិសមភាពសង្គម ទន្ទឹមនឹងទប់ស្កាត់ផងដែរនូវទំនាស់នានាទៅអនាគតផងដែរ។ យើងក៏សូមអបអរសាទចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចផ្តួចផ្តើមគំនិតដ៏មោះមុត/អង់អាចនេះ។

៦. ក្នុងឱកាសនេះ ដៃគូអភិវឌ្ឍន៍ចង់សួរសំណួរខ្លះថាតើបទបញ្ជានេះនឹងត្រូវយកទៅអនុវត្តន៍ដូចម្តេចខ្លះ។

- តើនៅចុងបញ្ចប់នៃយុទ្ធនាការនេះ ដីរដ្ឋដែលនៅសេសសល់ទាំងប៉ុន្មាន ជាពិសេសដីព្រៃ នឹងត្រូវបានកំណត់ព្រំប្រទល់ និងចុះបញ្ជី? តើផែនទីគំរបព្រៃរបស់កម្ពុជានឹងត្រូវបានធ្វើបច្ចុប្បន្នភាពដែរឬទេ?
- តើអាចដៃគូអភិវឌ្ឍន៍ អាចទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីការផ្អាកជាបណ្តោះអាសន្ននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងអំពីការពិនិត្យមើលស្ថានភាពនៃដីសម្បទានដែលបានផ្តល់រួចហើយដែរឬទេ។ ឧទាហរណ៍ តើដីសម្បទានសេដ្ឋកិច្ចនានាកំពុងស្ថិតក្រោមការពិនិត្យវិនិច្ឆ័យដែរឬទេ? បើមាន តើធ្វើឡើងដោយអ្នកណា?
- តើយុទ្ធនាការនេះនាំមកនូវព័ត៌មានច្បាស់លាស់អំពីចំណែកដីដែលមានសម្រាប់ធ្វើជាដីសម្បទានសង្គមកិច្ច និងដីសម្បទានសេដ្ឋកិច្ចដែរឬទេ ហើយតើនឹងមានការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចដែរឬទេ? តើព័ត៌មាននេះនឹងមានផ្សព្វផ្សាយជាសាធារណៈដែរឬទេ?
- តើនឹងមានការដោះស្រាយកន្លែងដែលស្ថិតក្នុងទំនាស់ដោយរបៀបណា? តើនឹងប្រើប្រាស់យន្តការដោះស្រាយដែលមានស្រាប់ដែរឬទេ?
- តើយុទ្ធនាការក្នុងការចុះបញ្ជីដីធ្លីជនជាតិដើមភាគតិចមានស្ថានភាពបែបណាហើយ? តើនឹងមានការស្នើសុំឲ្យអាជ្ញាធរខេត្តដាក់ចេញវិធានការការពារជាបណ្តោះអាសន្នចំពោះមុខដែរឬទេ សម្រាប់ដីធ្លីជនជាតិដើមដែលមានសិទ្ធិក្នុងការទទួល?
- តើការអនុវត្តបទបញ្ជានេះមានឥទ្ធិពលកម្រិតណាមកលើផែនការបង្កើនល្បឿនការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ?

៧. ដោយគិតគូរអំពីសារៈសំខាន់ និងការពាក់ព័ន្ធនៃបទបញ្ហានេះ នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ស្ថិរភាពសង្គម និងការគ្រប់គ្រងដីធ្លី ដៃគូអភិវឌ្ឍន៍ចង់នៅបន្តពាក់ព័ន្ធ និងចង់ពិភាក្សាអំពីថាតើកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ដទៃទៀតអាចបំពេញបន្ថែម បែបណាជាមួយបទបញ្ហានេះ។